ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ស្ពឺ**
សំណុំរឿងរដ្ឋប្បវេណីលេខ២១៣
ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣
សាលក្រមលេខ ១៤៤ "ខ"
ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣

# សាលក្រម
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ស្ពឺ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣។

**ចៅក្រមជំនុំជម្រះ**

លោក [redacted]អនុប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជី**

លោក [redacted]ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

-ដើមចោទឈ្មោះ [redacted]ចាន់ថន ភេទស្រី កើតនៅឆ្នាំ១៩៨៦ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅ[redacted]

អ្នកតំណាងដោយអាណត្តិ ៖

លោកមេធាវី [redacted] និងកញ្ញាមេធាវី [redacted]។ ទូរស័ព្ទលេខ ០១២ ២១៨១៩០/ ០១៦ ៦៧០ ០០៣។

-ចុងចម្លើយឈ្មោះ [redacted] សេងហាក់ ភេទប្រុស កើតនៅឆ្នាំ១៩៨៤ ជាតិខ្មែរ ទីលំនៅភូមិ[redacted]។

អ្នកតំណាងដោយអាណត្តិ ៖

លោកស្រីមេធាវី [redacted] ក្រុម [redacted]។ ទូរស័ព្ទលេខ ០១២ ៧០០៩០០។

**អង្គហេតុ និងចំណុចវិវាទ**

ក. ខ្លឹមសារនៃសាលក្រម និងការចាត់ចែងបន្ទាប់បន្សំដែលដើមចោទទាមទារឲ្យតុលាការចេញ

(១)- ដើមចោទឈ្មោះ [redacted]ចាន់ថន លែងលះពីចុងចម្លើយឈ្មោះ [redacted] សេងហាក់ ។

(២)-កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនស្រីរវាងដើមចោទ និងចុងចម្លើយទាំងបីនាក់



Scanned with CamScanner

មានឈ្មោះ [redacted] **គីមសុាំង** ភេទស្រី កើតនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨, ឈ្មោះ [redacted] **គីមស័ង** ភេទស្រី កើតនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ និងឈ្មោះ [redacted] **គីមស៊ីង** ភេទស្រី កើតនៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៣។

(៣)-បង្គាប់ឲ្យចុងចម្លើយបង់សោហ៊ុយ ដើម្បីគ្រប់គ្រងថែរក្សាកូនចំនួន ១២០០០០០រៀល ក្នុង០១ខែ ឲ្យទៅដើមចោទ តាមរយៈគណនី [redacted] ឈ្មោះ [redacted]CHANTHORN ។

(៤)- បែងចែកទ្រព្យសម្បត្តិរួម ៖

៤.១-ប្រគល់ទៅឲ្យដើមចោទ និងចុះបញ្ជីទៅឲ្យដើមចោទនូវទ្រព្យសម្បត្តិដូចខាងក្រោម ៖

ក/ ដី-ផ្ទះ ដែលមានក្បាលដីលេខ ៨៥ ស្ថិតនៅភូមិគោកសណ្ដែក ឃុំក្រាំងចេក ស្រុកឧដុង្គ (បច្ចុប្បន្នស្រុកសាមគ្គីមុនីជ័យ) ខេត្តកំពង់ស្ពឺ មានព្រំប្រទល់ខាងជើងទល់នឹង [redacted] ឃីម ៨៧ និង [redacted] ថាវី ១៤៥៨; ៨៦ ខាងត្បូងទល់នឹង [redacted] ស៊ាន់៨៤ ខាងកើតទល់នឹង [redacted] ថាវី ១៤៥៨ ខាងលិចទល់នឹងផ្លូវ; ៨៦។

ខ/ ដី ដែលមានក្បាលដីលេខ ៣៨៥ ស្ថិតនៅភូមិក្រាំងជ្រូក ឃុំក្រាំងចេក ស្រុកឧដុង្គ (បច្ចុប្បន្នស្រុកសាមគ្គីមុនីជ័យ) ខេត្តកំពង់ស្ពឺ មានព្រំប្រទល់ខាងជើងទល់នឹង [redacted] សុភាព ៣៨៦ ខាងត្បូងទល់នឹងផ្លូវ ខាងកើតទល់នឹងផ្លូវ ខាងលិចទល់នឹង [redacted] សុផល ៣៨៤។

គ/ ផ្ទះ ដែលមានក្បាលដីលេខ៩៣៣ ស្ថិតនៅភូមិព្រៃក្ដី សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០២០៥០៧-០៩៣៣ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១។

ឃ/ មុខរបរលក់ដូរគ្រឿងអលង្ការ និងគ្រឿងអលង្ការ (ប្លាទីន)។

ង/ ប្រាក់បានមកពីលក់សត្វជ្រូក កាលពីខែកក្កដា ឆ្នាំ២០២៣ ចំនួន៨.០០០.០០០រៀល។

៤.២- ប្រគល់ទៅឲ្យចុងចម្លើយ និងចុះបញ្ជីទៅឲ្យចុងចម្លើយ នូវទ្រព្យសម្បត្តិដូចខាងក្រោម ៖

ក/ ដីឡូតិ៍លេខ I-67 ស្ថិតនៅភូមិព្រៃទើ ភូមិព្រៃជ ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ (មានកិច្ចសន្យាទិញលក់ដី និងកក់ប្រាក់ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២)។

ខ/ មុខរបរចិញ្ចឹមជ្រូក សត្វជ្រូក សម្ភារ ព្រមទាំងរោងសម្រាប់ចិញ្ចឹមជ្រូក។

គ/ ប្រាក់បានមកពីលក់សត្វជ្រូក កាលពីខែកក្កដា ឆ្នាំ២០២៣ ចំនួន៨.០០០.០០០រៀល។

(៥)-ប្រាក់ប្រដាប់ក្ដី ជាបន្ទុករបស់ចុងចម្លើយ ។

## ខ. ដំណើររឿងក្ដី និងចំណុចវិវាទ

### ខ.១. ការសង្ខេបអំពីរឿងក្ដី

នៅក្នុងរឿងក្ដីនេះ ដើមចោទអះអាងថា ទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងខ្លួន និងចុងចម្លើយមិនចុះសម្រុងនឹងគ្នាទេ ពីព្រោះចុងចម្លើយប្រើអំពើហិង្សា យកខោអាវ ស្បែកជើង គប់ដើមចោទ យកទឹកជះលើដើមចោទ ប្រដាច់ខ្សែមុង ញីកញាប់ ជាន់លើដើមទ្រូង ចាប់ទាញដៃខ្ទប់នឹងទូ ទះ ៥កំភ្លៀង ។ ក្រៅពីការទាមទារលែងលះ ដើមចោទក៏បានទាមទារឲ្យកំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនទាំង៣ ទាមទារសោហ៊ុយបីបាច់ថែរក្សាកូន និងការបែងចែកទ្រព្យសម្បត្តិ ដែលជាការទាមទារបន្ទាប់បន្សំ។

### ខ.២. អង្គហេតុដែលជាមូលហេតុ ដើម្បីពិចារណាអំពីចំណុចវិវាទ



Scanned with CamScanner

ខ.២.១/ ដើមចោទបានរៀបការជាមួយចុងចម្លើយ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៧ ដើម្បីរួមរស់ជាប្ដីប្រពន្ធ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់លេខ ២៥ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៧។

ខ.២.២/ នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨ គូភាគីកើតបានកូនស្រីម្នាក់ឈ្មោះ [redacted] **គីមស៊ាំង**

ខ.២.៣/ នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ គូភាគីកើតបានកូនស្រីម្នាក់ឈ្មោះ [redacted] **គីមស៊ង**

ខ.២.៤/ នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៣ គូភាគីកើតបានកូនស្រីម្នាក់ឈ្មោះ [redacted] **គីមស៊ីង**

ខ.២.៥/ នៅកាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី១ ចុងចម្លើយបានឆ្លើយថាគ្មានមូលហេតុនៃការលែងលះ ហើយខ្លួនមិនព្រមលែងលះដើមចោទទេ។ នៅកាលបរិច្ឆេទបន្តទៀត ចុងចម្លើយបង្ហាញឆន្ទៈហាក់ស្ទាក់ស្ទើរអំពីការលែងលះ និងបានទទួលស្គាល់អង្គហេតុហិង្សា និងអង្គហេតុផ្សេងទៀត ប៉ុន្តែមានលក្ខណៈតិចតួចប៉ុណ្ណោះ។ ចំណែកឯដើមចោទបាននិយាយថា ខ្លួនមិនអាចបន្តចំណងអាពាហ៍ពិពាហ៍ជាមួយនឹងចុងចម្លើយបានតទៀតទេ។

**ខ.៣. ចំណុចវិវាទ និងការអះអាងរបស់ភាគីចំពោះចំណុចវិវាទ**

ដើមចោទ និងចុងចម្លើយបានលើកឡើងថា មិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ទេ គឺទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ពួកខ្លួនបានបែកបាក់ (អស់មនោសញ្ចេតនា) និងគ្មានសង្ឃឹមថា ជួបជុំគ្នាវិញបានទេ ដោយដើមចោទនិយាយថា បើឲ្យជួបជុំគ្នា មានតែចាំធ្វើបុណ្យសពរបស់ខ្លួនតែប៉ុណ្ណោះ។

ដូច្នេះតុលាការទទួលស្គាល់ថា មានអង្គហេតុដែលជាមូលហេតុនៃការលែងលះ ដូចចែងក្នុងចំណុច ង កថាខណ្ឌ១ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី មានន័យថា បណ្ដឹងទាមទារលែងលះរបស់ដើមចោទ មានមូលហេតុ។

ចំណុច១ នៃមាត្រា ៩៧៨ (មូលហេតុនៃការលែងលះគ្នា) នៃក្រមរដ្ឋប្បវេណីចែងថា ៖

១-ប្ដី ឬប្រពន្ធ អាចដាក់ពាក្យបណ្ដឹងលែងលះគ្នាបាន តែក្នុងករណីដែលកំណត់ខាងក្រោមនេះ ៖

ក-បើបានប្រព្រឹត្តអំពើផិត ទៅលើសហព័ទ្ធ។

ខ-បើបានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ។

គ-បើមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬរស់ អស់រយៈពេលជាង១(មួយ)ឆ្នាំ។

ឃ-បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង១(មួយ)ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍។

ង-ករណីផ្សេងទៀត ដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន។

ហេតុដូច្នេះចំណុចវិវាទនៅក្នុងរឿងក្ដីនេះ មានដូចតទៅ ៖

**ខ.៣.១/ ការកំណត់អ្នកមានអំណាចមេបា**

ខ.៣.១.១/ ការអះអាងរបស់ដើមចោទ

ដើមចោទនៅជិតកូន បានថែរក្សាកូនៗជាប្រចាំ មានចំណេះដឹងសមរម្យ និងមានទីលំនៅច្បាស់លាស់



Scanned with CamScanner

សម្រាប់ស្នាក់អាស្រ័យ រីឯចុងចម្លើយមិនសូវបាននៅជាមួយកូន ច្រើននៅតែកន្លែងចិញ្ចឹមសត្វជ្រូក មិនសូវមានឱកាសបានថែរក្សារូបកាយកូនទេ។ ដូច្នេះគួរតែដើមចោទ ជាអ្នកមានអំណាចមេបា។

ខ.៣.១.២/ ការអះអាងរបស់ចុងចម្លើយ

ចំពោះកូន ចុងចម្លើយស្នើសុំឲ្យតុលាការសម្រេចរក្សាស្ថានភាព ដូចមុនពេលបែកបាក់គ្នាដដែល។

**ខ.៣.២/ បន្ទុកលើសោហ៊ុយដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន)**

ខ.៣.២.១/ ការអះអាងរបស់ដើមចោទ

ដើមចោទមានមុខរបរលក់ប្លាទីន និងគ្រឿងប្លាទីន មានប្រាក់ចំណូលមែន ចំណែកចុងចម្លើយក៏មានមុខរបរ មានប្រាក់ចំណូលដែរ ហើយដោយកូនៗនៅលើខ្លួនបីបាច់ និងដើម្បីកូនបានចម្រើនវ័យល្អ ទាំងរូបកាយនិងចំណេះដឹង ដើមចោទសុំឲ្យចុងចម្លើយជួយផ្តល់ជូចការទាមទារ។

ខ.៣.២.២/ ការអះអាងរបស់ចុងចម្លើយ

ចុងចម្លើយមានមុខរបរមែន ប៉ុន្តែចំណូលមិនទៀងទាត់ទេ ដូចនេះសុំផ្តល់ទៅតាមលទ្ធភាពជាក់ស្តែង។

**ខ.៣.៣/ ការបែងចែកទ្រព្យសម្បត្តិ**

រវាងដើមចោទ និងចុងចម្លើយ មានទ្រព្យសម្បត្តិរួមដូចខាងក្រោម

-ដី,ផ្ទះ ដែលមានក្បាលដីលេខ ៨៥ ស្ថិតនៅភូមិគោកសណ្តែក ឃុំក្រាំងចេក ស្រុកឧដុង្គ (បច្ចុប្បន្នស្រុកសាមគ្គីមុនីជ័យ) ខេត្តកំពង់ស្ពឺ មានព្រំប្រទល់ខាងជើងទល់នឹង[redacted] ឃឹម ៨៧ និងរស់ ថាវី ១៤៩៨; ៨៦ ខាងត្បូងទល់នឹង[redacted]ស៊ាន់៨៤ ខាងកើតទល់នឹង[redacted]ថាវី ១៤៩៨ ខាងលិចទល់នឹងផ្លូវ; ៨៦

-ដី ដែលមានក្បាលដីលេខ ៣៨៥ ស្ថិតនៅភូមិក្រាំងជង្រុក ឃុំក្រាំងចេក ស្រុកឧដុង្គ (បច្ចុប្បន្នស្រុកសាមគ្គីមុនីជ័យ) ខេត្តកំពង់ស្ពឺ មានព្រំប្រទល់ខាងជើងទល់នឹង[redacted] សុភាព ៣៨៦ ខាងត្បូងទល់នឹងផ្លូវ ខាងកើតទល់នឹងផ្លូវ ខាងលិចទល់នឹង[redacted] សុផល ៣៨៤

-ផ្ទះ ដែលមានក្បាលដីលេខ ៩៣៣ ស្ថិតនៅភូមិព្រៃក្តី សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០២០៥០៧-០៩៣៣ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១

-មុខរបរលក់ដូរគ្រឿងអលង្ការ និងគ្រឿងអលង្ការ (ប្លាទីន)

-ដីឡូតិ៍លេខ I-67 ស្ថិតនៅភូមិព្រៃទើ ភូមិព្រៃជ ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ (មានកិច្ចសន្យាទិញលក់ដី និងកក់ប្រាក់ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២)

- មុខរបរចិញ្ចឹមជ្រូក សត្វជ្រូក សម្ភារ ព្រមទាំងរោងសម្រាប់ចិញ្ចឹមជ្រូក

- បំណុលជំពាក់ធនាគារ[redacted] ជំពាក់ថៅកែលក់គ្រឿងប្លាទីន, ជំពាក់លេងតុងទីន និងជំពាក់សម្ភារសំណង់ (យកមកប្រើក្នុងរោងចិញ្ចឹមសត្វជ្រូក)។

ខ.៣.៣.១/ **ការអះអាងរបស់ដើមចោទ**

-ដើមចោទទាមទារយកដី,ផ្ទះ ដែលមានក្បាលដីលេខ៨៥ , ដីដែលមានក្បាលដីលេខ ៣៨៥, ផ្ទះ ដែលមានក្បាលដីលេខ៩៣៣ ពីព្រោះខ្លួនជាអ្នកមានអំណាចមេបាលើកូន ត្រូវការផ្ទះឲ្យកូនស្នាក់នៅសមរម្យ មានសុខមាលភាព។



Scanned with CamScanner

ដី,ផ្ទះ ដែលមានក្បាលដីលេខ ៨៥ បានចុះបញ្ជីជាប្រព័ន្ធរួច តែមិនទាន់ទទួលបានប័ណ្ណ(ប្លង់)រឹងនៅឡើយ មានតែបង្កាន់ដៃ និងបានយកទៅដាក់បញ្ចាំ ធានាបំណុលចំនួន ៥ម៉ឺនដុល្លារអាមេរិក មានការប្រាក់ចំនួន ១៦ ៧១០,៥២$ នៅធនាគារ[redacted]រយៈពេល៦ឆ្នាំ គិតពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១។

ផ្ទះ ដែលមានក្បាលដីលេខ ៩៣៣ ប៉ុន្តែបង់រំលោះមិនទាន់ដាច់។

ដី ដែលមានក្បាលដីលេខ ៣៨៥ បានធ្វើប្លង់ជាប្រព័ន្ធ តែមិនទាន់បានទទួលប្លង់រឹងនៅឡើយ ដែលប្រាក់យកទៅទិញ ជាប្រាក់មួយផ្នែកនៃប្រាក់កម្ចី ដាក់ទ្រព្យខាងលើធានា។

-ដើមចោទទាមទារមុខរបរលក់ដូរគ្រឿងអលង្ការ និងគ្រឿងអលង្ការ (ប្លាទីន) ពីព្រោះជាមុខរបរដែលខ្លួនប្រកបជាអាជីពចិញ្ចឹមជីវិត តាំងពីដើមរៀងមក និងតទៅអនាគត។

-ដើមចោទសុខចិត្តទទួលរ៉ាប់រងបំណុលធនាគារទាំងពីរលើក បំណុលជំពាក់ថៅកែប្លាទីន និងតុងទីន។

ខ.៣.៣.២/ **ការអះអាងរបស់ចុងចម្លើយ**

ចុងចម្លើយទាមទារដី ផ្ទះ ដែលមានក្បាលដីលេខ ៩៣៣ និងដីឡូតិ៍ I-67 ចំណែកមុខរបរចិញ្ចឹមសត្វ រោង សម្ភារ សម្រាប់បំរើឲ្យការចិញ្ចឹមសត្វជ្រូក គ្រឿងអលង្ការប្លាទីន ត្រូវលក់យកមកបែងចែកគ្នា។

**ចំណុចផ្សេងទៀត (កត់សម្គាល់អំពីបំណុល) ៖**

ក/ បំណុលទី១ រួមគ្នាខ្ចីពីធនាគារ[redacted]ចំនួន ៥ម៉ឺនដុល្លារអាមេរិក មានការប្រាក់ចំនួន១៦ ៧១០,៥២$ រយៈពេល៦ឆ្នាំ (៧២ខែ) គិតពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១

ខ/ បំណុលទី២ រួមគ្នាខ្ចីពីធនាគារ[redacted]ចំនួន ៣ម៉ឺនដុល្លារអាមេរិក មានការប្រាក់ ៩៩២២$ រយៈពេល៦ឆ្នាំ (៧២ខែ) គិតពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ដោយដាក់ទ្រព្យជាកេរ្តិ៍ផ្ទាល់ខ្លួនរបស់ដើមចោទ (អំណោយពីឪពុកម្តាយ) ហើយយកទៅធ្វើជាទុនក្នុងមុខរបរចិញ្ចឹមសត្វជ្រូក និងមុខរបរលក់គ្រឿងប្លាទីន។

គ/ បំណុលទី៣ ជំពាក់គ្រឿងសំណង់សម្រាប់មុខរបរចិញ្ចឹមសត្វជ្រូកចំនួន ២.៨៧៧,៥$

ឃ/ បំណុលទី៤ ជំពាក់ថៅកែប្លាទីនចំនួន ១៩.៩៥៧$ ក្នុងមុខរបរលក់ប្លាទីន

ង/ បំណុលទី៥ ទាក់ទងនឹងតុងទីន នៅសល់ចំនួន ១ម៉ឺនដុល្លារអាមេរិក ដែលយកមកទិញផ្ទះ ដី ។

## សំអាងហេតុ

**ក. ការវិនិច្ឆ័យចំពោះការកំណត់អំពីអ្នកមានអំណាចមេបា**

**ក.១/ ការទទួលស្គាល់អង្គហេតុ**

អង្គហេតុដែលតុលាការទទួលស្គាល់តាមរយៈភស្តុតាង និងសេចក្តីថ្លែងការណ៍ ថា កូនទាំងបីនាក់ ជាកូនរបស់ដើមចោទ និងចុងចម្លើយគឺ ៖

ក.១/ សំបុត្របញ្ជាក់កំណើតលេខ ២៤០ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ (សៀវភៅបញ្ជាក់កំណើតលេខ០៣/២០១៨) ,

ក.២/ សំបុត្រកំណើតលេខ ០៣ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ (សៀវភៅកំណើតលេខ០១/២០១២)

ក.៣/ សំបុត្របញ្ជាក់កំណើតលេខ ១៦៩ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ (សៀវភៅបញ្ជាក់កំណើតលេខ០២/២០១៣) ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំក្រាំងចេក



Scanned with CamScanner

ក.៤/ ដើមចោទនៅជិតកូនៗ ជាងចុងចម្លើយ ដែលមានមុខរបរនៅឆ្ងាយពីផ្ទះ ដែលត្រូវបំពេញជារៀងរាល់ថ្ងៃ ។

**ក.២/ សេចក្តីសន្និដ្ឋាន**

-ដើមចោទមានមុខរបរត្រឹមត្រូវ មានចំណូល ចំណែកចុងចម្លើយមានមុខរបរដែរ ប៉ុន្តែចំណូលមិនទៀងទាត់ ដើមចោទមានចំណេះដឹង មានផ្ទះស្នាក់នៅសមរម្យ និងនៅក្បែរកូនៗបានជាប់លាប់ ។

-ចុងចម្លើយមានមុខរបរ តែចំណូលមិនទៀងទាត់ មានមុខរបរ ដែលមិនសូវបាននៅជិតកូន ថែរក្សាកូនបានជិតដល់ ។

ដូច្នេះហើយ ផ្អែកតាមស្ថានភាពរបស់គូភាគី ឃើញថា ស្ថានភាពរបស់ដើមចោទ មានលក្ខណៈល្អប្រសើរជាងចុងចម្លើយ មួយវិញទៀត តាមរយៈការសាកសួរកូនៗ ឃើញថា កូនៗចង់ទៅរស់នៅជាមួយម្តាយ ហើយការទាមទាររបស់ចុងចម្លើយ សុំទុកកូនឲ្យនៅដដែលដូចស្ថានភាពមុនបែកបាក់ គឺជាការទាមទារផ្ទុយច្បាប់ ពីព្រោះកាលណាអាពាហ៍ពិពាហ៍បែកបាក់ កូនៗដែលជាអនីតិជន មិនអាចនៅក្នុងអំណាចមេបារួមបានទេ។

តាមមាត្រា ១០៣៧ ចំណុច៣ នៃក្រមរដ្ឋប្បវេណី , មាត្រា ២២ កថាខណ្ឌ១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

**ខ. <u>ការវិនិច្ឆ័យចំពោះបន្ទុកលើសោហ៊ុយដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន</u> (សោហ៊ុយចិញ្ចឹមបីបាច់កូន)**

**ខ.១/ ការទទួលស្គាល់អង្គហេតុ**

-ដើមចោទមានមុខរបរលក់គ្រឿងប្លាទីន និងលក់បន្ទាប់បន្សំ (ខោអាវ ស្បែកជើង) មានប្រាក់ចំណូលមែន ប៉ុន្តែកូនទាំងបីនាក់ស្ថិតក្នុងបន្ទុករបស់ខ្លួន ដែលសុទ្ធតែនៅអនីតិជន ត្រូវការរៀនសូត្រ ហើយខ្លួនក៏រ៉ាប់រងបំណុលធនាគារ និងបំណុលផ្សេងទៀត។

-អំឡុងពេលបែកបាក់គ្នា កូនទាំងអស់ស្ថិតនៅលើដើមចោទចិញ្ចឹម បីបាច់ ពោលគឺចំណាយលើកូនជាបន្ទុករបស់ដើមចោទ។

-ការសាកសួរទៅលើចុងចម្លើយៗ អះអាងពីចំណូលរបស់ខ្លួន មិនទៀងទាត់ អាស្រ័យពេលលក់ជ្រូកទើបមានប្រាក់ ហើយសុំបង់ទៅឲ្យដើមចោទតាមលទ្ធភាព។

**ខ.២/ សេចក្តីសន្និដ្ឋាន**

តាមអង្គហេតុខាងលើ តុលាការយល់ឃើញថា ការទាមទាររបស់ដើមចោទមានលក្ខណៈត្រឹមត្រូវ ហើយចុងចម្លើយក៏មានប្រាក់ចំណូលរបស់ខ្លួនដែរ ប៉ុន្តែតុលាការនឹងកំណត់ចំនួនពិតប្រាកដអំពីប្រាក់នេះសម្រាប់កូនម្នាក់ៗ ដែលដល់នីតិភាពតាមអាយុរៀងៗខ្លួន ។ មាត្រា ២២ កថាខណ្ឌ២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

**គ. <u>ការវិនិច្ឆ័យចំពោះការបែងចែកទ្រព្យសម្បត្តិ</u>**

**គ.១. ការទទួលស្គាល់អង្គហេតុ**



Scanned with CamScanner

គ.១.១/ រវាងដើមចោទ និងចុងចម្លើយ មានទ្រព្យសម្បត្តិរួមដូចក្នុងចំណុច ខ.៣.៣ ខាងលើ ហើយភស្តុតាងដែលតុលាការទទួលស្គាល់ថា ទ្រព្យមួយចំនួនមានបន្ទុក (ដាក់បញ្ចាំ) គឺ-កិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ (អេស៊ីលីដា) ទឹកប្រាក់៥០ ០០០$ និងកាលវិភាគសងប្រាក់, បង្កាន់ដៃតម្កល់ទ្រព្យលេខ 0509FL 21006292 ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ ([redacted],កិច្ចសន្យាបង្កើតហ៊ីប៉ូតែកចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ ([redacted]), វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០២០៥០៧-០៩៣៣, កិច្ចសន្យាលក់ផ្ទះល្វែងភ្លោះ នៅសង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១, កិច្ចសន្យាខ្ចីប្រាក់ (ឥណទានអាជីវកម្មខ្នាតតូច) ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ចំនួន ៣០ ០០០$ ([redacted]), កិច្ចសន្យាបង្កើតហ៊ីប៉ូតែក, លិខិតកំណត់សម្គាល់ប្លង់, កាលវិភាគសងប្រាក់កម្ចី។

គ.១.២/ ចុងចម្លើយទាមទារយកផ្ទះលេខ ៩៣៣ និងដីឡូត៍លេខ I-67 ក្រៅពីនេះចុងចម្លើយសុខចិត្តប្រគល់ទៅឲ្យដើមចោទ ដោយលើកហេតុផលថា ដើមចោទត្រូវគ្រប់គ្រង ថែរក្សាកូន និងទទួលយកបំណុល ក៏ប៉ុន្តែផ្ទះលេខ ៩៣៣ ក៏នៅជាប់បន្ទុកដែរ ហើយដោយសារតែដើមចោទសុខចិត្តរ៉ាប់រងបំណុល ដែលកើតឡើងដោយសារដាក់បញ្ចាំ ដូច្នេះគប្បីប្រគល់ដីនេះទៅឲ្យដើមចោទ ។

គ.១.៣/ ប្រាក់ដែលបានមកពីការលក់សត្វជ្រូកចំនួន ១៦.០០០.០០០រៀល គូភាគីបានបែងចែកគ្នារួចហើយ។

**គ.២. ការវិនិច្ឆ័យ**

ជាគោលការណ៍ទ្រព្យសម្បត្តិដែលមានក្នុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួម (មាត្រា៩៧៣ នៃក្រមរដ្ឋប្បវេណី) ហើយនៅពេលលែងលះគ្នា ដើមចោទ និងចុងចម្លើយមានសិទ្ធិទទួលយក ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម (មាត្រា ៩៨០ ចំណុច ខ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណី)។ គោលការណ៍នេះ គឺមកពីប្ដីប្រពន្ធត្រូវរួមរស់នៅជាមួយគ្នា ត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមក (មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណី) ។ ដូច្នេះក៏អាចយល់ឃើញថា ជាទ្រព្យដែលកើតមកពីការសហការគ្នារវាងអ្នកទាំង២ ហើយនៅពេលដែលលែងលះគ្នាក៏ត្រូវយកទ្រព្យសម្បត្តិទាំងនេះ មកជម្រះបញ្ជីដែរ។

**គ.៣. វិធីបែងចែក**

. យោងតាមចំណុច គ.១ ខាងលើ តុលាការទទួលស្គាល់តាមការទាមទាររបស់ដើមចោទ ពីព្រោះដើមចោទត្រូវបីបាច់ ថែរក្សាកូន និងដោះបន្ទុកដែលមានលើទ្រព្យទាំងនោះតែម្នាក់ឯង។ ចំណែកឯមុខរបរ មិនអាចយកមកលក់ ហើយបែងចែកគ្នាបានទេ ពីព្រោះវាខុសពីស្ថានភាពជាក់ស្ដែង ដែលអ្នកទាំង២ មានជំនាញក្នុងមុខរបររៀងៗខ្លួន ប្រសិនបើលក់ប្ដូរយកជាប្រាក់ នោះខូចទ្រង់ទ្រាយ ឬបាត់មុខរបរហើយ ឧ. រុះរើរោងទ្រុងជ្រូក យកឈើ ស័ង្កសី...មកលក់។

ដូច្នេះគប្បីរក្សាមុខរបរឲ្យនៅដដែល និងប្រគល់ទៅគូភាគី តាមមាត្រា ៩៨០ កថាខណ្ឌ ២ ចំណុច(ខ) វាក្យខណ្ឌ២ នៃក្រមរដ្ឋប្បវេណី។ មាត្រា ២២ កថាខណ្ឌ១ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល។

**ឃ. ស្ដីពីបន្ទុកប្រាក់ប្រដាប់ក្ដី**





Scanned with CamScanner

ដោយហេតុថា តុលាការទទួលស្គាល់តាមការទាមទាររបស់ដើមចោទដោយភាគច្រើន ដូច្នេះស្ដីពីប្រាក់ប្រដាប់ក្ដី គួរតែជាបន្ទុករបស់ចុងចម្លើយ( តាមមាត្រា ៦៤ ចំណុច១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

## សេចក្ដីសម្រេចបញ្ចប់

១/- ដើមចោទឈ្មោះ [redacted] ចាន់ថន លែងលះពីចុងចម្លើយឈ្មោះ [redacted] **សេងហាក់**។

២/- កំណត់ដើមចោទឈ្មោះ [redacted] **ចាន់ថន** ជាអ្នកមានអំណាចមេបាលើកូន ៖

-ឈ្មោះ [redacted] **គីមស៊ាំង** ភេទស្រី កើតនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨

-ឈ្មោះ [redacted] **គីមស៊ីង** ភេទស្រី កើតនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១

-ឈ្មោះ [redacted] **គីមស៊ុីង** ភេទស្រី កើតនៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៣

និងមានករណីយកិច្ចបីបាច់ ថែរក្សា រហូតកូនដល់នីតិភាព ។

៣/- បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] **សេងហាក់** បង់សោហ៊ុយសម្រាប់បីបាច់ ថែរក្សាកូនទាំងបី ក្នុងម្នាក់ៗចំនួន ៣០០.០០០(សាមសិបម៉ឺន)រៀល ជារៀងរាល់ខែ ទៅឲ្យដើមចោទឈ្មោះ [redacted] **ចាន់ថន** រហូតកូនដល់នីតិភាពរៀងៗខ្លួន។

៤/- ចុងចម្លើយឈ្មោះ [redacted] **សេងហាក់** មានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងកូន ឬយកកូនមកលេងនៅផ្ទះរបស់ខ្លួនបាននៅរៀងរាល់ថ្ងៃអាទិត្យ ចាប់ពីម៉ោង០៧-០០នាទីព្រឹក ដល់ម៉ោង ០៥-០០នាទីល្ងាច ក្នុង០១ខែចំនួន ០២(ពីរ)ដង ។

៥- បែងចែក និងប្រគល់ទៅឲ្យដើមចោទ ឈ្មោះ [redacted] **ចាន់ថន** នូវទ្រព្យសម្បត្តិដូចខាងក្រោម ៖

៥.១/ ដី-ផ្ទះ ដែលមានក្បាលដីលេខ ៨៥ ស្ថិតនៅភូមិគោកសណ្ដែក ឃុំក្រាំងចេក ស្រុកឧដុង្គ (បច្ចុប្បន្នស្រុកសាមគ្គីមុនីជ័យ) ខេត្តកំពង់ស្ពឺ មានព្រំប្រទល់ខាងជើងទល់នឹង [redacted] យឹម ៨៧ និង [redacted] ថាវី ១៤៩៨; ៨៦ ខាងត្បូងទល់នឹងហេង ស៊ាន់៨៤ ខាងកើតទល់នឹងរស់ ថាវី ១៤៩៨ ខាងលិចទល់នឹងផ្លូវ; ៨៦។

៥.២/ ដី ដែលមានក្បាលដីលេខ ៣៤៥ ស្ថិតនៅភូមិក្រាំងជង្រុក ឃុំក្រាំងចេក ស្រុកឧដុង្គ (បច្ចុប្បន្នស្រុកសាមគ្គីមុនីជ័យ) ខេត្តកំពង់ស្ពឺ មានព្រំប្រទល់ខាងជើងទល់នឹង [redacted] សុភាព ៣៤៦ ខាងត្បូងទល់នឹងផ្លូវ ខាងកើតទល់នឹងផ្លូវ ខាងលិចទល់នឹងសន សុផល ៣៤៤។

៥.៣/ ផ្ទះ ដែលមានក្បាលដីលេខ ៩៣៣ ស្ថិតនៅភូមិព្រៃក្ដី សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០២០៥០៧-០៩៣៣ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ។

៥.៤/ មុខរបរលក់ដូរគ្រឿងអលង្ការ និងគ្រឿងអលង្ការ (ប្លាទីន)។

៦/- បែងចែក និងប្រគល់ទៅឲ្យចុងចម្លើយឈ្មោះ [redacted] **សេងហាក់** នូវទ្រព្យសម្បត្តិដូចខាងក្រោម ៖

៦.១/ ដីឡូតិ៍លេខ I-67 ស្ថិតនៅភូមិព្រៃទើ ភូមិព្រៃជ ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ (មានកិច្ចសន្យាទិញលក់ដី និងកក់ប្រាក់ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២) ។



Scanned with CamScanner

៦.២/ មុខរបរចិញ្ចឹមសត្វជ្រូក សត្វជ្រូក សម្ភារ ព្រមទាំងរោងសម្រាប់ចិញ្ចឹមសត្វជ្រូក និងបំណុលគ្រឿងសំណង់ក្នុងមុខរបរនេះ។

៧/- ដើមចោទឈ្មោះ [redacted] ចាន់ថន ត្រូវទទួលបន្ទុកប្រាក់កម្ចីពីធនាគារទាំង២ លើក, បំណុលជំពាក់ចៅកែប្លាទីន, និងគុងទីន។

៨/- ចំណុចទី៥.១ នៃចំណុចទី៥ ខាងលើ អាចអនុវត្តបណ្តោះអាសន្នបាន តាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី, មាត្រា ១៣ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

៩/- ច្រានចោលការទាមទារផ្សេងពីនេះ របស់គូភាគី។

១០/-ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ ។

**ចៅក្រមជំនុំជម្រះ**

(ហត្ថលេខា និងត្រា) លោក [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃ............ ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តកំពង់ស្ពឺ,ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០២៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner